**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០១៣/២៤ ក.ប/ស.ជ.ណ.ខ.៩

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបន្ថែមម៉ោងធ្វើការរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនបងប្អូនកម្មករនិយោជិត ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងសាធារណជន ឱ្យបានជ្រាបថា ដើម្បីផ្តល់សេវាប្រឹក្សាយោបល់ផ្នែកច្បាប់ ទទួលពាក្យបណ្តឹង និងអន្តរាគមន៍នានាពាក់ព័ន្ធនឹងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យការងារ និងសន្តិសុខសង្គម ឱ្យកាន់តែឆាប់រហ័ស ក្រសួងបានបន្ថែមម៉ោងធ្វើការ ដូចខាងក្រោម៖

១.ពេលព្រឹក ចូលមុន ៣០នាទី គឺចាប់ពីម៉ោង ៧:០០នាទីព្រឹក

២.ពេលរសៀល ថែមចំនួន ៥ម៉ោង គឺចាប់ពីម៉ោង ៥:៣០នាទីរសៀល ដល់ម៉ោង ១០:៣០នាទីយប់ និង

៣.ចុងសប្តាហ៍ ថែមចំនួន ២ថ្ងៃ គឺថ្ងៃសៅរ៍ និងថ្ងៃអាទិត្យ ចាប់ពីម៉ោង ៧:០០នាទីព្រឹក ដល់ម៉ោង ១០:៣០នាទីយប់។

ជាមួយគ្នានេះ ក្រសួងក៏មានក្រុមការងារឆ្លើយតប និងផ្តល់ព័ត៌មានតាមរយៈប្រព័ន្ធ **Hotline** លេខ **"១២៩៧"** ឬ **"១២៨៦"** ដោយធ្វើការ ២៤ម៉ោងក្នុងមួយថ្ងៃ និង ៧ថ្ងៃក្នុងមួយសប្តាហ៍។

បន្ថែមពីនេះ ដើម្បីធ្វើការសាកសួរ និងទទួលបានព័ត៌មានផ្សេងៗ បងប្អូនកម្មករនិយោជិត ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងសាធារណជន ក៏អាចទាក់ទងមកក្រសួង តាមរយៈក្រុមតេឡេក្រាម **"សម្រាប់និយោជក"** (https://t.me/EmployerChat) ឬក្រុមតេឡេក្រាម **"សម្រាប់កម្មករនិយោជិត"** (https://t.me/KhmerWorkerChat) ដែលអាចភ្ជាប់តាមរយៈការស្កេន QR Code ខាងក្រោម។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមបងប្អូនកម្មករនិយោជិត ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថាន និងសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃសុក្រ ៣រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២៤

**រដ្ឋមន្ត្រី**

**ហេង សួរ**

"សម្រាប់និយោជក"

"សម្រាប់កម្មករនិយោជិត"

**កន្លែងទទួល :**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩*